ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

...ជាការខេត្តបាត់ដំបង
...សំណុំរឿងព្រហ្មទណ្ឌ
...: ៩១៩ ចុះថ្ងៃទី ១១
...វិច្ឆិកា ឆ្នាំ ២០០៥
...ាលក្រមព្រហ្មទណ្ឌ
...២៣ "ក" ចុះថ្ងៃទី ៣០
... មករា ឆ្នាំ ២០០៦

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈនៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted]ជាប្រធានតុលាការខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted]ជាព្រះរាជអាជ្ញារងអមតុលាការខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**ដើម្បីជំនុំជំរះ**

រឿងក្តីព្រហ្មទណ្ឌលេខ ៩១៩ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ ។

១-ឈ្មោះ ស ជរ ហៅ ណា ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ី មិនពិតប្រាកដ មានទីកន្លែងកំណើតនៅសង្កាត់លេខ ៣ ក្រុងភ្នំពេញ មានកិរិតវប្បធម៌ថ្នាក់ទី ០១ថ្មី កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃ នៅមិនពិតប្រាកដ មានប្រពន្ធឈ្មោះ សទ ជ (រ) មានកូន ០១នាក់ មានឪពុកឈ្មោះ ៩ ភ (រ) មានម្តាយឈ្មោះ ស ឆ (រ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារតាមអំណាចសាលក្រមព្រហ្មទណ្ឌចំនួន ០២ ។ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅចំណុចផ្ទះជួលក្នុងស្ថានីយរថភ្លើងបាត់ដំបង និង ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅអាគារឃុំខ្លួន នៃពន្ធនាគារខេត្តបាត់ដំបង តាមដីកាឃុំខ្លួនលេខ : ៥៦៧ ដ.ឃ.ខ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

ត្រូវចោទពីបទ ចោរកម្ម តាមបទបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។ ប្រព្រឹត្តនៅវត្តឯករស្មី ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

**ជនរងគ្រោះ :**

១-ព្រះសង្ឃ ព្រះនាម ៩ សណ ព្រះជន្ម ២៥ព្រះវស្សា គង់នៅវត្តឯករស្មី ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

២-ព្រះសង្ឃ ព្រះនាម ឈ ផ មានព្រះជន្ម ២២ព្រះវស្សា គង់នៅវត្តឯករស្មី



Scanned with CamScanner

ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

## ការប្រព្រឹត្តិទៅរបស់ជនជាប់ចោទ

កាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ពេលយប់ជ្រៅជនជាប់ចោទឈ្មោះ **ស ជ៖** បានទៅលួចកង់ចំនួន ពីរគ្រឿង របស់ព្រះសង្ឃទុកនៅក្នុងកុដិលេខ ១៥ នៃវត្តឯករស្មី ឃុំទួលតាឯក ស្រុកបាត់ដំបង ដោយជនជាប់ចោទជិះកង់ម្តងមួយៗ ទៅទុកនៅផ្ទះរបស់ខ្លួន ។ លុះព្រឹកឡើងឈ្មោះ **ស ជ៖** យកកង់ ១ ទៅលក់ នៅសល់មួយគ្រឿងទុកជិះ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនបានតែម្តង ។

-តាមរបាយការណ៍លេខ ២៧៥/០៩ ព្រ.ទ.ក.ស ចុះថ្ងៃ ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកិរិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានបញ្ជាក់ កាលពីថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥ អង្គភាពខ្លួនបាននាំឈ្មោះ **ស ជ៖** ទៅសាកសួរ ក៏ឈ្មោះ **ស ជ៖** នេះបានឆ្លើយសារភាពថា : ខ្លួនតាំងពីចេញពីពន្ធនាគារ ខ្លួនបានលួចទ្រព្យសម្បត្តិប្រជាពលរដ្ឋចំនួន ០៥លើក ។

-តាមរបាយការណ៍លេខ ២៧៨ ដ.ប ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានបញ្ជាក់ថា មានព្រះសង្ឃពីរអង្គគង់នៅវត្តឯករស្មី បានមកប្តឹងនគរបាលថា មានចោរលួចកង់ពីរគ្រឿង ដែលទុកនៅក្រោមកុដិលេខ ១៥ ។ ហើយក្នុងរបាយការណ៍បញ្ជាក់ថា ជនសង្ស័យឈ្មោះ **ស ជ៖** បានឆ្លើយសារភាពថា ខ្លួនបានលួចកង់របស់ព្រះសង្ឃពិតមែន ។

-តាមកំណត់ហេតុឃាត់ខ្លួនជនសង្ស័យ ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកិរិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានបញ្ជាក់ថា : បានធ្វើការដកកង់មួយគ្រឿងម៉ាក (កង់តូក) ពណ៌ទឹកប្រាក់ផ្ទៃមេឃ ដៃត្រង់ ពាក់ព័ន្ធករណីលួចនៅវត្តទួលតាឯក ។

## នៅចំពោះមុខតុលាការពេលសវនាការ

-ជនជាប់ចោទឈ្មោះ **ស ជ៖** បានឆ្លើយសារភាពថា កាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ពេលយប់ខ្លួនបានដើរកាត់វត្តទួលតាឯក បានឃើញនៅក្រោមកុដិលោកមួយមានកង់ជាច្រើនគ្រឿង ពេលនោះខ្លួនឃើញកង់ពីរគ្រឿងអត់មានចាក់សោរ ក៏ខ្លួនលួចកង់ទាំងពីរគ្រឿងនោះម្តងមួយៗយកទៅទុកផ្ទះខ្លួន ។ លុះព្រឹកឡើងខ្លួនលក់កង់ ១គ្រឿង នៅ ១គ្រឿងទុកជិះ ក៏ត្រូវនគរបាលចាប់ខ្លួន ឃាត់ខ្លួនដកយកកង់ ១គ្រឿងពីខ្លួនវិញ ។

-តាមសង្ឃដីកាព្រះសង្ឃព្រះនាម **ឈ ផ** បញ្ជាក់ថា ព្រះអង្គបានបាត់កង់០១គ្រឿង ដែលទុកនៅក្រោមកុដិ លុះប៉ុន្មានថ្ងៃក្រោយមកនគរបាលបានប្រគល់កង់នោះឱ្យព្រះអង្គវិញហើយ ។

-តាមសង្ឃដីកាព្រះសង្ឃព្រះនាម **ម សណ** បានមានសង្ឃដីកាថា ព្រះអង្គបានបាត់កង់ ០១គ្រឿង កាលពីយប់ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ដោយមិនដឹងអ្នកណាជាអ្នកលួចទេ ។

## តំណាងអយ្យការសន្និដ្ឋានទោសថា

មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ស ជ៖** ពីបទ ចោរកម្ម ប្រព្រឹត្តនៅវត្តឯករស្មី ឃុំទួលតាឯក ស្រុកខេត្តបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។ បទល្មើសមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ក្នុងនាមតំណាងអយ្យការសុំតម្កល់បទចោទទុកជាបានការពេញទាំងមូល ។ ជនជាប់ចោទឈ្មោះ **ស ជ៖** ត្រូវបានតុលាការខេត្តបាត់ដំបងកាត់ឱ្យជាប់គុកចំនួន ពីរដង



Scanned with CamScanner

រួចហើយ ពីបទ ឆបោក និង បទក្រុមជនប្រដាប់អាវុធ ទើបតែចេញពីគុក ហើយប្រព្រឹត្តបទល្មើសទៀត ។ ស្នើសុំតុលាការ ផ្តន្ទាទោសឈ្មោះ **ស ដរ** ដាក់ពន្ធនាគារកំណត់ពី ០៣ឆ្នាំ ដល់ ០៥ឆ្នាំ ពីបទចោទ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ **ស ដរ** បាននិយាយជាសំដីចុងក្រោយថា សុំតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ

-បានស្តាប់ក្រឡាបញ្ជីអានចម្លើយឱ្យការណ៍របស់ជនរងគ្រោះ

-បានស្តាប់ការសួរដេញដោល

-បានពិនិត្យកំណត់ហេតុ ឯកសារ ភស្តុតាងនានា

-បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ

-បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-បានពិចារណាត្រឹមត្រូវហើយ

## តុលាការខេត្តបាត់ដំបងយល់ឃើញថា

-ពិតជាកើតមាននូវអំពើចោរកម្មនៅវត្តឯករស្មី ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ប្រាកដមែន ។

-អំពើចោរកម្មដែលកើតនៅទីកន្លែង និង ពេលវេលាដូចខាងលើពិតជាប្រព្រឹត្តឡើងដោយឈ្មោះ **ស ដរ** បានលបលួចកង់ ០២គ្រឿងជារបស់ព្រះសង្ឃព្រះនាម **ឈ ផ** មួយគ្រឿង និង របស់ព្រះសង្ឃព្រះនាម **ខ សឈា** មួយគ្រឿង ដែលទុកក្នុងកុដិយកទៅចាត់ចែងលក់ចាយវាយបម្រើផលប្រយោជន៍សួនតួបុគ្គលប្រាកដមែន ។

-អំពើដែលឈ្មោះ **ស ដរ** បានប្រព្រឹត្តនៅទីកន្លែង និង ពេលដូចខាងលើនេះ មានធាតុផ្សំគ្រប់គ្រាន់ជាបទចោរកម្មដូចមានបញ្ញត្តិក្នុងមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ឈ្មោះ **ស ដរ** ជាសមត្ថជន គាត់មានអាយុ ៣៤ឆ្នាំ មានស្មារតីជានាល្អ គាត់បានលបលួចយកកង់ជាទ្រព្យសម្បត្តិអ្នកដទៃយកទៅលក់បម្រើផលប្រយោជន៍សួនតួបុគ្គលខ្លួនបានសម្រេច ។

## យល់ឃើញថា

មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ **ស ដរ** ពីបទ ចោរកម្ម ប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចការចោទប្រកាន់របស់ស្ថាប័នអយ្យការប្រាកដមែន ។

**ភស្តុតាងដាក់បន្ទុកមាន :**

-ចម្លើយដោះសាររបស់ជនជាប់ចោទបានឆ្លើយបញ្ជាក់យ៉ាងច្បាស់ពីអំពើដែលខ្លួនបានប្រព្រឹត្តថា នៅក្នុងយប់ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ខ្លួនពិតជាបានលួចយកកង់ចំនួន ០២គ្រឿងដែលគេដាក់ទុកនៅក្នុងកុដិ នៅក្នុងវត្តឯករស្មី ឃុំទួលតាឯក ស្រុកបាត់ដំបង ហើយវាស៊ីសង្វាក់គ្នាទៅនឹងចម្លើយឱ្យការណ៍របស់ជនរងគ្រោះទាំងពីរនាក់ និង ឯកសារភស្តុតាងនានាធ្វើដោយនគរបាលយុត្តិធម៌បានធ្វើ ។

-ចម្លើយឱ្យការរបស់ជនរងគ្រោះឈ្មោះ **ឈ ផ** និង ឈ្មោះ **ខ សឈា** បានឆ្លើយឱ្យការណ៍យ៉ាងច្បាស់



Scanned with CamScanner

លាស់ ហើយវាស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទ និង ហេតុការណ៍ កាលៈទេសៈនៃបទល្មើស ។

-កំណត់ហេតុ ឯកសារភស្តុតាងនានាធ្វើដោយនគរបាលយុត្តិធម៌ ។

**យល់ឃើញថា**

ជនជាប់ចោទគាត់មានជីវភាពក្រខ្សត់ គាត់ពុំដែលមានទោសពីមុនមក ការប្រព្រឹត្តិរបស់គាត់បានសំរេចកម្មវត្ថុ នៃបទល្មើសមានតម្លៃទាប ជាហេតុតុលាការយកមកពិចារណាជាស្ថានសម្រាលទោសបាន ។

ជនជាប់ចោទបានប្រព្រឹត្តបទល្មើសចោរកម្មលួចយកកង់ ០២គ្រឿង នៅក្នុងកន្លែងតែមួយ តែពេលវេលាខុសគ្នា និង បានប្រព្រឹត្តបទល្មើសក្នុងករណីមិនរៀងចាល ។ ដោយគាត់ធ្លាប់បានទទួលទណ្ឌកម្មតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៥២ "យ" ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ រយៈពេល ០២ឆ្នាំ ទើបតែចេញពីគុក នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៥ ក៏លូកដៃប្រព្រឹត្តបទល្មើសទៀត ជាហេតុតុលាការមកពិចារណាជាស្ថានទម្ងន់ទោសក្នុងការសំរេចពីទណ្ឌកម្ម ។

**ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោស : ឈ្មោះ ស ជ៖ ហៅ ណា ដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំគត់ ដោយគិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។ ពីបទ : ចោរកម្ម ប្រព្រឹត្តនៅវត្តឯករស្មី ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោសមានបញ្ញត្តិក្នុងមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ ស ជ៖ ហៅ ណា ។ បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជំរះ**

[redacted] [redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលក្រម ឱ្យសំរេចតាមសាលក្រមនេះ និង ឱ្យអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ជួយអនុវត្តឱ្យបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៦*

**ជ. ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

*បាត់ដំបង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៦*

**ប្រធានតុលាការខេត្ត**

[redacted]



Scanned with CamScanner